ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ០៦

ព្រឹត្តិបត្រព័ត៌មាន

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

សកម្មភាព ការងារ

Work Activities

ប្រចាំខែមិថុនា ឆ្នាំ២០១២

មាតិការអត្ថបទ

កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល

ល.រ	ឈ្មោះអត្ថបទ	លេខទំព័រ
១-	សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ	១
២-	សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០	៣
៣-	សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់	៥
៣-	ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែឧសភា ឆ្នាំ២០១២	៧
៤-	សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	១៤

សេចក្តីព្រាងច្បាប់ស្តីពី

ការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ

កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ភាំង តុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ចុនឆឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងឧទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការពារជាតិ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសដាក់ឲ្យប្រើតាំងពីឆ្នាំ១៩៩៣ មានរយៈពេលជិត២០ឆ្នាំ ហើយ។ រដ្ឋធម្មនុញ្ញបានបញ្ញត្តិឲ្យបង្កើតស្ថាប័នកំពូលៗដ៏សំខាន់មួយចំនួនរួមទាំង "ឧត្តមក្រុមប្រឹក្សាការពារជាតិ"ផង។ ក្នុងរយៈពេលបីអាណត្តិកន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំតាក់តែងនិងសុំការអនុម័តច្បាប់ថ្មីៗជាច្រើន ជាពិសេសច្បាប់សម្រាប់រៀបចំស្ថាប័នកំពូលៗដូចជា៖

-ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ១៩៩៤

-ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សារាជសម្បត្តិ ឆ្នាំ២០០៤។

ដោយឡែកច្បាប់ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ" ពុំទាន់បានបង្កើតតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនៅឡើយ។

នៅក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី១ ឧត្តមក្រុមប្រឹក្សាការពារជាតិត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៦ គឺក្រោយពេលប្រទេសកម្ពុជាបានទទួលឯករាជ្យតែជាង២ឆ្នាំប៉ុណ្ណោះ ហើយត្រូវបានកែប្រែនៅខែកញ្ញា ឆ្នាំ១៩៥៨។ នៅក្នុងរបបសាធារណរដ្ឋខ្មែរបានកែប្រែសមាសភាពស្ថាប័នកំពូលនេះឡើងវិញនៅខែមេសា ឆ្នាំ១៩៧០ និងបានកែប្រែម្តងទៀតនៅឆ្នាំ១៩៧៣ ហើយបានដំណើរការរហូតដល់ឆ្នាំ១៩៧៥។ ចាប់តាំងពីឆ្នាំ១៩៧៥ រហូតបច្ចុប្បន្ន ប្រទេសកម្ពុជាពុំបានបង្កើតស្ថាប័នកំពូលនេះនៅឡើយទេ។ ដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជានិងពង្រឹកនីត្យានុកូលភាពនៃការដឹកនាំកងយោធពលខេមរភូមិន្ទក្នុងការបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមរបស់ខ្លួនក្នុងកិច្ចការពារប្រទេស ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិត្រូវបានតាក់តែងឡើងស្របតាមកាលៈទេសៈចាំបាច់នេះ។

មូលដ្ឋានជាសារវន្តនៃការរៀបចំសេចក្តីព្រាងច្បាប់នេះ គឺមាត្រា២៤ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថា "ព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិដែលនឹងត្រូវបង្កើតឡើងដោយច្បាប់។ ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភានិងព្រឹទ្ធសភា " ។ មាត្រា៨និងមាត្រា៥២ នៃរដ្ឋធម្មនុញ្ញបានចែងផងដែរថា "ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជាអ្នកធានាឯករាជ្យ អធិបតី និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវការពារនីត្យានុកូលភាព របស់ខ្លួន[1]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងច្បាប់នេះទាំងស្រុង។

[1] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ។

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០

កាលពីថ្ងៃទី១៩និងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោង១៥:០០នាទីនិងវេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងទេសចរណ៍។

ក្រសួងទេសចរណ៍បានរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០ ហើយបានធ្វើជូនក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធររាជធានី ខេត្ត ផ្នែកឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ ដើម្បីសុំយោបល់ ពិគ្រោះយោបល់ និងឆ្លងកាត់កិច្ចប្រជុំជាច្រើនដង ពិសេសសិក្ខាសាលាថ្នាក់ជាតិកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ និងថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ បានប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឯកសារផែនការយុទ្ធសាស្ត្រនេះរៀបចំឡើងក្នុងគោលបំណងសំខាន់ៗរួមមាន៖

- រៀបចំបង្កើតឯកសារមានលក្ខណៈជាយុទ្ធសាស្ត្របន្ថែមទៀត សំខាន់ជំរុញការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ។
- បញ្ជាក់ច្បាស់ថែមទៀតការប្តេជ្ញាចិត្ត រួបរួមគ្នាក្នុងការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកសាធារណៈ ឯកជន ដៃគូអភិវឌ្ឍ និងប្រជាពលរដ្ឋ។
- បង្ហាញច្បាស់ក្របខ័ណ្ឌនៃការអភិវឌ្ឍ ចក្ខុវិស័យ ទិសដៅយុទ្ធសាស្ត្រ និងការដាក់ចេញវិធានការ និងផែនការអនុវត្ត។
- លើកកម្ពស់ការយល់ដឹងនិងការចូលរួមថែមទៀតក្នុងការអភិវឌ្ឍទេសចរណ៍ ពីគ្រប់ភាគីពាក់ព័ន្ធពិសេសការកៀរគរជំនួយអភិវឌ្ឍន៍បន្ថែមពីដៃគូអភិវឌ្ឍ។

វិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ គឺជាវិស័យអាទិភាពមួយត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា។ វិស័យទេសចរណ៍រួមចំណែកកសាងសេដ្ឋកិច្ច សង្គម ផ្តល់ឱកាសការងារ ប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រ។ ទេសចរណ៍ត្រូវបានទទួលស្គាល់ថា " មាសបៃតង" ជាផ្នែកដ៏ សំខាន់នៃសេដ្ឋកិច្ចបៃតង ដែលចំណូលនៃវិស័យនេះ ត្រូវបានចាក់បញ្ចូលភ្លាមៗទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ រួមចំណែកជំរុញ កំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស.)និងធ្វើឲ្យមានលំនឹងផ្នែកជញ្ជីងពាណិជ្ជកម្ម។ ការអភិវឌ្ឍទេសចរណ៍ប្រកប ដោយនិរន្តរភាពនិងការទទួលខុសត្រូវ រួមចំណែកយ៉ាងសកម្មដល់កិច្ចអភិវឌ្ឍ ថែរក្សា ការពារ និងអភិរក្សសម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ។ ម្យ៉ាងទៀត ការរីកលូតលាស់នៃទេសចរណ៍ជួយលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ ការពង្រឹង និងពង្រីកមិត្តភាព សាមគ្គីភាព កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងអន្តរជាតិ។

ឆ្នាំ២០១១ កន្លងទៅ ព្រះរាជាណាចក្រកម្ពុជាបានទទួលភ្ញៀវទេសចរអន្តរជាតិមកទស្សនាប្រមាណជាង ២,៨៨ លាននាក់ បង្កើតបានចំណូលទេសចរណ៍ជាង ១ ៩០០ លានដុល្លារ។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១២ នេះ សភាពការណ៍ ទេសចរណ៍កាន់តែល្អប្រសើរ ដោយបន្តកើនឡើង ២៧% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន ជាមួយនឹងភ្ញៀវទេសចរជិត ១លាននាក់។ យើងសង្ឃឹមថា ឆ្នាំ២០១២ នឹងសម្រេចបានចំនួនទេសចរប្រមាណ ៣,៤លាននាក់។

ឆ្នាំ២០២០ គ្រោងនឹងទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧លាននាក់ ព្រមជាមួយនឹងទេសចរណ៍ក្នុងស្រុក ប្រមាណជា ៨ ទៅ ១០ លាននាក់។ ចំណូលទេសចរណ៍ក្នុងសេដ្ឋកិច្ចនឹងកើនឡើងដល់៥០០០លានដុល្លារក្នុងមួយឆ្នាំ។ គិតចាប់ពីឆ្នាំ២០២០ ដែលចំណូលនេះនឹងរួមចំណែកយ៉ាងសំខាន់ដល់កំណើននៃផលិតផលក្នុងស្រុកសរុបនិងផ្តល់ឱកាស ការងារប្រមាណ៨០ម៉ឺនទៅ១លានការងារក្នុងវិស័យទេសចរណ៍(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងផែនការនេះ ហើយបានសម្រេចកែសម្រួលពាក្យពេចន៍ និងឃ្លាប្រយោគមួយចំនួន ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេចរណ៍២០១២-២០២០។

សេចក្តីព្រាងច្បាប់ស្តីពី

ការត្រួតពិនិត្យផលិតផលថ្នាំជក់

កាលពីថ្ងៃទី២១ ថ្ងៃទី២២ ថ្ងៃទី២៧ ថ្ងៃទី២៨ ខែមិថុនា និងថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី និងវេលាម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណាលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ស៊ឹម ប៉ុណ្ណាឫទ្ធិ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសុខាភិបាល។

ការប្រើប្រាស់ផលិតផលថ្នាំជក់ផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។ នៅទូទាំងពិភពលោកមានអ្នកជក់ថ្នាំជក់ជាង ១ពាន់លាននាក់ ដែលក្នុងនោះចំនួនជាងពាក់កណ្តាលត្រូវស្លាប់។ ថ្នាំជក់សម្លាប់មនុស្ស ៥,៤ លាននាក់ជារៀងរាល់ឆ្នាំ(បើគិតជាមធ្យមមនុស្សម្នាក់ស្លាប់ក្នុង៦វិនាទី) ដែលលើសពីចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍ របេងនិងគ្រុនចាញ់រួមបញ្ចូលគ្នាទៅទៀត។

ក្នុងចំណោមមនុស្សជាង ៥លាននាក់ ដែលបានស្លាប់ដោយសារថ្នាំជក់ជារៀងរាល់ឆ្នាំមានស្ត្រីប្រហែល ១,៥ លាននាក់។ ប្រសិនបើមិនមានវិធានការណ៍បន្ទាន់ទេ នោះថ្នាំជក់នឹងបន្តសម្លាប់មនុស្ស៨លាននាក់ជារៀងរាល់ឆ្នាំនៅមុនឆ្នាំ២០៣០ ដែលក្នុងនោះមាន ២,៥ លាននាក់ជាស្ត្រី។ ថ្នាំជក់ធ្វើឲ្យខូចខាតសេដ្ឋកិច្ចសង្គម ដូចជាការចំណាយលើការព្យាបាលជំងឺបណ្តាលមកពីការប្រើប្រាស់ផលិតផលថ្នាំជក់ ការចំណាយដោយប្រយោលដូចជាការខាតបង់ទាក់ទងនឹងការធ្លាក់ចុះផលិតភាព ឬការបាត់បង់ប្រាក់កម្រៃដោយសារការស្លាប់និងភាពមានជំងឺ។

រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារីនិងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្មថ្នាំជក់ ហើយបច្ចុប្បន្ននេះក្រសួងសុខាភិបាលដែលមានមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពជាលេខាធិការដ្ឋាន បានសហការជាមួយស្ថាប័នពាក់ព័ន្ធតាមដានអនុវត្តអនុក្រឹត្យនេះ។ តាមរយៈការអង្កេតស្រាវជ្រាវនៅទូទាំងប្រទេសអំពីការប្រើប្រាស់ថ្នាំជក់ទៅលើមនុស្សពេញវ័យដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការចំនួនពីរលើក លើកទី១ នៅឆ្នាំ២០០៥-២០០៦ និងលើកទី២ នៅឆ្នាំ២០១០-២០១១ បានបង្ហាញថា ប្រៀងឡង់នៃការ

ប្រើប្រាស់ថ្នាំជក់ក្នុងចំណោមមនុស្សពេញវ័យអាយុចាប់ពី ១៨ឆ្នាំឡើងទៅ បានថយចុះពី ៤៨,៩៨% មក ៤៣,៣% ចំពោះបុរស និងពី ២០,៣% មក ១៧,២% ចំពោះស្ត្រី។ ដើម្បីកាត់បន្ថយការប្រើប្រាស់ថ្នាំជក់នៅប្រទេសកម្ពុជា និងផ្តល់ការគាំទ្រដល់អនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់របស់អង្គការសុខភាពពិភពលោក រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានឯកភាពឲ្យបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីអប់រំនិងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ តាមសេចក្តីសម្រេចលេខ៣៥ ស.ស.រ. ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៥ កន្លងមកនេះ។ នេះបានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារ និងលើកកម្ពស់សុខភាពជូនប្រជាជនកម្ពុជា។

ឆ្លើយតបនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាលបានសហការជាមួយក្រសួងនានាជាសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីអប់រំនិងកាត់បន្ថយថ្នាំជក់ បានខិតខំរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ មានគោលបំណងការពារសុខភាពសាធារណៈ បរិស្ថាន និងកាត់បន្ថយផលប៉ះពាល់ទៅលើសេដ្ឋកិច្ច និងសង្គមនិងមានគោលដៅកំណត់វិធានការក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យផលិតផលថ្នាំជក់ លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណៈជនអំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតថ្នាំជក់ សហការជាមួយបណ្តាលក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងអង្គការដៃគូនានា(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អប្រសើរឡើងដើម្បីជូនទៅប្រជុំអន្តរក្រសួង។

អង្គប្រជុំជំនាញបច្ចេកទេសនឹងបន្តការពិភាក្សាលើសេចក្តីច្បាប់នេះនៅពេលក្រោយទៀត។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែឧសភា ឆ្នាំ២០១២*

របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែឧសភា ឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០១២ ដែលដឹកនាំដោយឯកឧត្តម **ឃឹម ណុលឆ្នា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ **ថយចុះ** ១,១% ធៀបនឹងខែមុន ប៉ុន្តែ**កើនឡើង** ២,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល ១២ខែ)។ ក្រុមទំនិញដែលបណ្តាលឲ្យមានការថយចុះសន្ទស្សន៍ថ្លៃខែ**ឧសភាធៀបនឹងមេសា** មានដូចជាក្រុមម្ហូបអាហារ ដែលរួមចំណែក ៣៣% ក្រុមដឹកជញ្ជូន ៣០% ក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត ១៩% និងក្រុមភោជនីយដ្ឋានរួមចំណែក ១៤%។

ការឡើងថ្លៃនៃក្រុមទំនិញ និងមុខទំនិញសំខាន់ៗធៀបនឹងខែដូចគ្នាឆ្នាំមុន

ក្រុមទំនិញ:	
ម្ហូបអាហារ: +២,២%	ការដឹកជញ្ជូន: +៣,៦%
ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន: +១,៤%	ភោជនីយដ្ឋាន: +២,៧%
ទំនិញនិងសេវាកម្មផ្សេងៗ: +៥,៨%។	

មុខទំនិញ:	
សាច់គោស្រស់: +១៤%	បន្លែ: +៨,៦%
ឧស្ម័ន: +០,៨%	ប្រេងសាំង: +៤,៨%
ប្រេងម៉ាស៊ូត: +៥,៨% ។	

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំង៥ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០-២០១២

ឆ្នាំ	ធៀបនឹង...	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា[P]	កក្កដា[P]	សីហា[P]	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	ប្រចាំឆ្នាំ
២០១២	ខែដូចគ្នាឆ្នាំមុន	៥,៨%	៥,៤%	៥,៤%	៤,៨%	២,២%	**៥,០%**	**៦,១%**	**៦,០**					
	ខែមុន	១,០	០,៤	០,៦%	០,៥%	-១,១%	**០,៨%**	**១,៨%**	**០,៤**					
២០១១	ខែដូចគ្នាឆ្នាំមុន	៣,៣%	៣,៨%	៣,៨%	៥,២%	៦,៥%	៧,១%	៧,១%	៦,៤%	៦,៧%	៥,៣%	៥,៦%	៤,៩%	៥,៥%
	ខែមុន	០,២%	០,៧%	០,៧%	១,១%	១,៤%	០,៥%	០,៦%	០,២%	១,០%	០,១%	-០,៧%	-០,៨%	
២០១០	ខែដូចគ្នាឆ្នាំមុន	៦,៩%	៧,៣%	៦,៧%	៥,៣%	៤,៥%	២,៥%	១,៦%	១,៧%	១,៩%	៣,៦%	៣,២%	៧,៣%	៤%
	ខែមុន	០%	០,៣%	០,៦%	-០,៣%	០,២%	០%	០,៥%	០,៩%	០,៧%	១,៤%	-១,០%	-០,២%	

P: តួលេខខែ មិថុនា កក្កដា និងសីហាឆ្នាំ២០១២ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១១ និង២០១២ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)



ក្រាហ្វបង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១១ និង ២០១២។ ក្រាហ្វក៏បង្ហាញផងដែរ នូវអត្រាអតិផរណាព្យាករបីខែទៅមុខ (ធៀបនឹងខែដូចគ្នាឆ្នាំមុន) ក្នុងឆ្នាំ២០១២។

➡**អត្រាប្តូរប្រាក់៖**

ប្រភេទ	អត្រាខែឧសភា ២០១២	អត្រាខែមេសា ២០១២	អត្រាខែឧសភា ២០១១	ប្រភេទ	អត្រាខែឧសភា ២០១២	អត្រាខែមេសា ២០១២	អត្រាខែឧសភា ២០១១
រ/ដុល្លារ	៤០៦៥រ/១$	៤០២៥រ/១$	៤០៨០រ/១$	បាត/ដុល្លារ	៣១,៨៧បាត/១$	៣០,៧៣បាត/១$	៣០,៣១បាត/១$
រ/បាត	១២៧រ/១បាត	១៣១រ/១បាត	១៣៥រ/១បាត	ដុង/ដុល្លារ	២០៨៦០ដុង/១$	២០៨៣០ដុង/១$	២០៥១០ដុង/១$
រ/ដុង	០,១៩៥រ/១ដុង	០,១៩៣រ/១ដុង	០,១៩៨រ/១ដុង				

២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុង**ខែឧសភាឆ្នាំ២០១២ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳***ចំណូលថវិកាជាតិអនុវត្តបាន ៦១៩,៧ ពាន់លានរៀល*** *(មធ្យមប្រចាំខែ ៧០% នៃគម្រោង) ក្នុងនោះ* **ចំណូលចរន្ត ៦១៩,៧ ពាន់លានរៀល** (មធ្យមប្រចាំខែ ១០១% នៃគម្រោង) និង**ពុំមានចំណូលមូលធនទេ**។

↳បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ**ថយចុះ ១៦,៥% ប៉ុន្តែកើនឡើង ១៣% *ធៀបនឹងខែដូចគ្នាឆ្នាំមុន*។ កំណើនធៀបនឹងខែឧសភាឆ្នាំមុន ជារួមបណ្តាលមកពីចំណូលចរន្តកើនឡើង ៣១%។

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ និង ២០១២ (ពាន់លានរៀល)



- នៅក្នុងចំណូលចរន្ត៖
  - ✓ចំណូលសារពើពន្ធមានចំនួន ៥៣៦,២ ពាន់លានរៀល ធៀបនឹងខែមុន ថយចុះ ២០% ប៉ុន្តែកើនឡើង ៣៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
  - ✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៨៣,៥ ពាន់លានរៀល កើនឡើង ២៩% ធៀបនឹងខែមុន និងកើនឡើង ៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)		ក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)	
➢ ពន្ធ និងអាករគយ: +៧%	(+១៥%)	➢ នេសាទ: +១៧៧%	(-៦៧%)
➢ ចំណូលពន្ធដារ: -៣១%	(+៦៣%)	➢ រុក្ខាប្រមាញ់ : +២២%	(-៥៤%)
➢ ចំណូលសារពើពន្ធផ្សេងៗ: -១៥%	(-១៧%)	➢ អាកាសចរណ៍ស៊ីវិល: +៤៦៥%	(-១៣%)
✧ កាស៊ីណូ : -៤%	(0%)	➢ ផលទុនទេសចរណ៍: +៧0%	(+១២៦0%)
✧ អាជ្ញាបណ្ណក្នុងស្រុក : -៣៥%	(-៥៥%)	➢ប្រៃសណីយ៍ និងទូរគមនាគមន៍: -៣៦%	(-៤%)
✧ ការគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -២១%	(-២២%)	➢អាករស្តានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): 0%	(+៧៧%)

- ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៦៤៧ ពាន់លានរៀល (*មធ្យមប្រចាំខែ ៥0% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៥៣៦ ពាន់លានរៀល(*មធ្យមប្រចាំខែ ៧៦% នៃគម្រោង*) និង**ចំណាយមូលធន** ១១១ ពាន់លានរៀល។
- *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** ថយចុះ ១៦% ប៉ុន្តែកើនឡើង ៤១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការថយចុះនៃ**ចំណាយថវិកាជាតិ**ធៀបនឹងខែមុន ជាចំបងបណ្តាលមកពីចំណាយចរន្ត ថយចុះ ២៦% ។
- *តុល្យភាពថវិកាជាតិនៃខែឧសភាមាន* ***ឱនភាព ២៧*** *ពាន់លានរៀល*។

៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភា ឆ្នាំ ២០១២ មានលក្ខណៈដូចខាងក្រោម៖

- រូបិយវត្ថុ M_2 មានចំនួន **២៥៨៨២** ពាន់លានរៀល កើនឡើង ២,២% ធៀបនឹងខែមុន និងកើនឡើង ២0% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- កំណើនរូបិយវត្ថុ M_2 ធៀបនឹងខែមុន ជារួមបណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង ១,៥% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ៣,២%។
- យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុង និងក្រៅធនាគារ**មានចំនួន **១៨,៦**% នៃរូបិយវត្ថុ M_2 និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨១,៤%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែឧសភា២0១២



សមាមាត្រចំនួនប្រាក់រៀល និងរូបិយវត្ថុ M_2												
ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
	១៩,២%	១៨,៣%	១៩,៦%	១៩,៣%	១៨,៦%							
ប្រាក់រៀលក្រៅធនាគារ	១៥,២%	១៥,២%	១៥,៣%	១៤,៨%	១៤,៧%							

បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែ ឧសភា២០១២: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន



- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣១១៩ **លានដុល្លារ** ថយចុះ ២,៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន **៨៣៦៧ ពាន់លានរៀល** កើនឡើង ២% ធៀបនឹងខែមុន និងកើនឡើង ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ ជារួមមានការកើនឡើង*** ។ ក្នុងខែនេះមានចំនួន **១៩៩៨៤ ពាន់លានរៀល** កើនឡើង ៣,៦% ធៀបនឹងខែមុន និងកើនឡើង ៤៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** (ខែមីនា មេសា និងឧសភាមិនទាន់មានតួលេខ)
- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** (ខែមេសា និងឧសភាមិនទាន់មានតួលេខ)

៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែឧសភា ឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតកម្មនេសាទមានចំនួន **៦៣,៥ ពាន់តោន** កើនឡើង ៩% ធៀបនឹងខែមុន និងកើនឡើង ២៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- **ឧស្សាហកម្ម៖**
  - ✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៦៨,៤ GWh កើនឡើង២% ធៀបនឹងខែមុន និងកើនឡើង ១៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ១១,៧ GWh កើនឡើង ២០% ធៀបនឹងខែមុន និងកើនឡើង កើនឡើង ១២២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣១២ លានដុល្លារ ថយចុះ ៤% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម៖

ប្រភេទ	ចំនួន—ឧសភា២០១២	ចំនួន—មេសា២០១២	ចំនួន—ឧសភា២០១១
▪ រោងចក្រថ្មី			

ទំនិញ	%ធៀបនឹងខែមុន	%ធៀបនឹងខែដូចគ្នាឆ្នាំមុន	ទំនិញ	%ធៀបនឹងខែមុន	%ធៀបនឹងខែដូចគ្នាឆ្នាំមុន
វាយនភណ្ឌនិងស្បែកជើង	+៥៤%	+១៨%	ផលិតផលឈើកែឆ្នៃ	-៣៦%	-៩៧%
កៅស៊ូ	+១៨១%	+១៣%	អង្ករ	-0,៤%	-៤២%
ផលិតផលនេសាទ	-១៩%	-៦៩%			

➡ ក្នុងខែឧសភានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៩១០ ពាន់លានរៀល ស្មើនឹង ២២៧ លានដុល្លារ ស.រ.អ.។

៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

ល.រ.	សូចនាករ	ធៀបនឹងខែមុន	ធៀបនឹងខែដូចគ្នាឆ្នាំមុន	កំណត់សម្គាល់
១	ថ្លៃសាច់គោស្រស់	+៥%	+១៤%	—
២	អាករនាំចេញ	+១៤៨%	-៤៨%	ថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន **ក្នុងខែ**មីនា មេសា និង ឧសភា ឆ្នាំ ២០១២
៣	ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក	**-៣៥**%	**-៥៥**%	ថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន **ក្នុងខែ** មេសា និងឧសភា ឆ្នាំ ២០១២
៤	ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី)	**-៧៩**%	**-៦៣**%	បើសរុបរយៈពេលប្រាំខែដើមឆ្នាំដូចគ្នា : ឆ្នាំ២០១១ មានចំនួន ១២៣ រីឯឆ្នាំ២០១២ មានចំនួន ៨៣
៥	ឧស្សាហកម្មធុនតូច និងសប្បកម្ម (បន្ត)	**-៣៨**%	**-៥0**%	បើសរុបរយៈពេលប្រាំខែដើមឆ្នាំដូចគ្នា : ឆ្នាំ២០១១ មានចំនួន ៧៨ រីឯឆ្នាំ២០១២ មានចំនួន ៣៥
៦	ការនាំចេញអង្ករ	-0.៤%	-៤២%	ថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន **ក្នុងខែ**មីនា មេសា និង ឧសភា ឆ្នាំ ២០១២

៧) ស្ថានីអង្គប្រជុំ និងការសន្និដ្ឋាន

អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

១) ក្នុងខែឧសភា ឆ្នាំ២០១២ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញមានសភាពធូរស្រាល។ ទំនិញប្រើប្រាស់ឡើងថ្លៃតែ ២,២%ប៉ុណ្ណោះ ធៀបនឹងខែដូចគ្នាឆ្នាំមុន និងចុះថ្លៃ ១,១% ធៀបនឹងខែមុន ជាចំបងបណ្តាលមកពីការធ្លាក់ថ្លៃនៃប្រេង ឥន្ធនៈ ដែលជះឥទ្ធិពលបន្តមកលើការដឹកជញ្ជូន និងទំនិញប្រើប្រាស់ផ្សេងៗ។

២) មានភាពមិនស៊ីគ្នារវាងតួលេខនៃ ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនបានចុះ បញ្ជីបង់ពន្ធដារតាមរបបពិតនៅអគ្គនាយកដ្ឋានពន្ធដារ។

សេចក្តីសន្និដ្ឋាន៖

គួរបង្កើតសេវាកម្ម ***ច្រកចេញចូលតែមួយ*** សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីបង់ពន្ធដារតាមរបបពិត។

សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១២

ល.រ	កាលបរិច្ឆេទ	សកម្មភាព
១	០៥/០៦/១២ រយៈពេល ០១ថ្ងៃ	ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន NiDA និងអគ្គនាយកដ្ឋានរាជកិច្ច ជាមួយសាជីវកម្មអន្តរជាតិប្រទេសចិន (IPPR) ដើម្បីពិនិត្យលើប្លង់ដំបូង នៃគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។
២	០៦/០៦/១២ រយៈពេល ០១ថ្ងៃ	បន្តដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន NiDA និងអគ្គនាយកដ្ឋានរាជកិច្ច ជាមួយសាជីវកម្មអន្តរជាតិប្រទេសចិន (IPPR) ដើម្បីពិនិត្យលើប្លង់ ដំបូងនៃគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។
៣	០៧/០៦/១២ ម៉ោង ០៨ : ៣០ នាទី	ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។
៤	០៧/០៦/១២ ម៉ោង ១៥ : ០០ នាទី	បន្តដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន NiDA និងអគ្គនាយកដ្ឋានរាជកិច្ច ជាមួយសាជីវកម្មអន្តរជាតិប្រទេសចិន (IPPR) ដើម្បីពិនិត្យលើប្លង់ ដំបូងនៃគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។
៥	០៨/០៦/១២ រយៈពេល ០១ថ្ងៃ	បន្តដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន NiDA និងអគ្គនាយកដ្ឋានរាជកិច្ច ជាមួយសាជីវកម្មអន្តរជាតិប្រទេសចិន (IPPR) ដើម្បីពិនិត្យលើប្លង់ ដំបូងនៃគម្រោងសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។
៦	១១/០៦/១២ ម៉ោង ១៥ : ៣០ នាទី	ដឹកនាំកិច្ចប្រជុំដើម្បីពិភាក្សាលើគម្រោង ការងារសាងសង់សំណង់គ្រប់គ្រងទឹកក្នុងតំបន់សៀមរាប-អង្គរ មុនពេលប្រជុំពេញអង្គគណៈកម្មការដេញថ្លៃ នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។
៧	១២/០៦/១២ ម៉ោង ១០ : ០០ នាទី	ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖ ១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល។ ២-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។
៨	១២/០៦/១២ ម៉ោង ១៥ : ០០ នាទី	ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។
៩	១២/០៦/១២ ម៉ោង ១៩ : ០០ នាទី	ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim Chon Song អ្នកគ្រប់គ្រងក្រុមហ៊ុនម៉ាន់ស៊ូដេញ្ជាតិច និងសហការី នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។
១០	១៤/០៦/១២ ម៉ោង ០៨ : ៣០ នាទី	ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ ២០១១ នៃការអនុវត្តជយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគេត្រា។
១១	១៥/០៦/១២ ម៉ោង ១៥ : ០០ នាទី	ដឹកនាំកិច្ចប្រជុំគណៈកម្មការដេញថ្លៃ សម្រាប់ការងារសាងសង់សំណង់គ្រប់គ្រងទឹកក្នុងតំបន់ សៀមរាប-អង្គរ នៅទីស្តីការគណៈរដ្ឋមន្ត្រី។
១២	២៨/០៦/១២ ម៉ោង ០៧ : ០០ នាទី	ចូលរួមជាកិត្តិយសក្នុងពិធីមិទ្ទិញអបអរសាទរខួបលើកទី៦១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា នៅបរិវេណខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា (ចំការមន)។
១៣	២៨/០៦/១២ ម៉ោង ១៥ : ៣០ នាទី	ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖ ១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០។ ២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីបរិស្ថាន និងសុខភាព។ ៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្តាបត្យករកម្ពុជា។ ៤-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

ព្រឹត្តិបត្រព័ត៌មាន

នាយកគ្រប់គ្រងទូទៅ:	ឯកឧត្តម គីម សយសាម៉ាឡែន	អនុប្រធាន ក.ស.វ.
និពន្ធនាយក:	ឯកឧត្តម ច័ន្ទ គិរុណា	អគ្គលេខាធិការ ក.ស.វ.
និពន្ធអត្ថបទ:	ឯកឧត្តម អេង វត្តមុនី	អគ្គលេខាធិការរង ក.ស.វ.
វិភាគស្ថានភាពសេដ្ឋកិច្ច:	ឯកឧត្តម ម៉ម សារិទ្ធ	សមាជិកបម្រុង ក.ស.វ.
ទំនាក់ទំនងនិងបោះពុម្ពផ្សាយ:	លោក ម៉ក់ ចារ៉ា	ប្រធានផ្នែក ក.ស.វ.
បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល:	លោក សយ ឥសា	អនុប្រធានផ្នែក ក.ស.វ.
យកព័ត៌មាននិងថតរូប:	លោក មុត កក្កដា	មន្ត្រី ក.ស.វ.

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in